# អត្ថបទសារពត៍មាន
# " ការធ្វើការងារប្រាំបីម៉ោង ក្នុងមួយថ្ងៃ "
# ទិវាពលកម្មអន្តរជាតិ ០១ ឧសភា ២០០៧

**០១ ឧសភា ២០០៧:** ក្នុងឱកាសខួបលើកទី១២១ នៃទិវាពលកម្មអន្តរជាតិ ០១ ឧសភា ២០០៧ ដែលជាថ្ងៃមួយដ៏សំខាន់បំផុត សំរាប់ កម្មករនៅជុំវិញពិភពលោក ចូលរួមរំលឹកនូវប្រវត្តិតស៊ូនៃការទាមទារនូវការធ្វើការងារប្រាំបីម៉ោងក្នុងមួយថ្ងៃរបស់ កម្មករនៅសហរដ្ឋអាមេរិកនោះ កម្មករ-កម្មការិនីនៅតាមបណ្តារោងចក្រកាត់ដេរនៅជុំវិញទីក្រុងភ្នំពេញ រួមជាមួយនឹងសមាជិក-សមាជិកានៃ "បណ្តាញការងារស្ត្រី " បានរួមគ្នារៀបចំទិវាពលកម្ម អន្តរជាតិ ក្រោមប្រធានបទ "**ការធ្វើការងារប្រាំបីម៉ោងក្នុងមួយថ្ងៃ** "។ ទិវានេះ ក៏មានការចូលរួមពីសំណាក់កសិករមកពីបណ្តាខេត្តមួយចំនួន និងវត្តមានរបស់អង្គការមិនមែនរដ្ឋាភិបាលនានា ដែលអ្នកចូលរួមទាំងអស់មានចំនួនប្រមាណ ប្រាំពីររយនាក់ (៧០០នាក់)។ កម្មវិធីនេះ ធ្វើការបង្ហាញ អំពីស្ថានភាពលក្ខ័ណការងារនៅក្នុងរោងចក្រ ប្រាក់ឈ្នួល ម៉ោងធ្វើការ ស្ថានភាពរស់នៅ និងអំពើហឹង្សា ដែលកម្មករ-កម្មការិនីប្រឈមមុខតាមរយៈការសំដែងរឿងខ្លី ចំរៀង និងអាយ៉ៃ ជាដើម។

លក្ខខណ្ឌការងាររបស់កម្មករតាមបណ្តារោងចក្រនានាត្រូវបានផ្លាស់ប្តូរក្រោយពេលដែលកិច្ចព្រមព្រៀងពហុសសៃ ត្រូវបានបញ្ចប់កាលពីចុងឆ្នាំ២០០៤កន្លងមកនេះ។ កម្មករភាគច្រើនជួបប្រទះនូវបញ្ហាលំបាក ដូចជាការផ្លាស់ប្តូរពីកម្មករពេញសិទ្ធិទៅជាកម្មករបណ្តែត រឺក៏ទៅជាកម្មករកិច្ចសន្យាជំនួសវិញ។ កម្មករថ្មីៗដែលរោងចក្រជួល គឺក្នុងលក្ខខណ្ឌជាកម្មករកិច្ចសន្យារយៈពេលខ្លី ហើយត្រូវធ្វើថ្មីឡើងវិញនៅរៀងរាល់ ប្រាំមួយខែ បីខែ ពីរខែ រឺមួយខែម្តង។ កម្មករកិច្ចសន្យាមិនបានទទួលការការពារដោយច្បាប់ការងារកម្ពុជា គ្មានសិទ្ធិគាំទ្រនូវអត្ថប្រយោជន៍នានា ដែលគួរតែទទួលបានឡើយ។ ខណៈពេលដែលប្រាក់កំរៃរបស់កម្មករជាច្រើនគិតតាមអត្រាការងារដែលពួកគេផលិតបាន តំលៃបុងនៃផលិតផលមានការធ្លាក់ចុះជាងមុន តែការកំណត់បរិមាណផលិតផលកម្មករត្រូវធ្វើមានការកើនឡើងជាលំដាប់។

*"នៅក្នុងរោងចក្ររបស់ខ្ញុំ មានកម្មករកិច្ចសន្យាត្រូវបានថៅកែជួលឱ្យធ្វើការច្រើនជាងកម្មករពេញសិទ្ធិ។ កម្មករកិច្ចសន្យាខ្លះបានធ្វើការដោយមានកិច្ចសន្យាអស់រយៈពេលបីឆ្នាំហើយ តែនៅតែមិនទាន់បានពេញសិទ្ធិ។*

*ពួកគេត្រូវផ្ចិតមេដៃ ដើម្បីបន្តកុងត្រារៀងរាល់១-២ខែម្តង។ កម្មករកិច្ចសន្យាភាគច្រើនធ្វើការនៅផ្នែកកាត់ និងផ្នែកពិនិត្យ "* កម្មករដែលធ្វើការនៅរោងចក្រនៅតំបន់ទួលសង្កែ, របាយការណ៍នៃការតាមដានលក្ខខណ្ឌការងារ របស់អង្គការកម្មវិធីស្ត្រីដើម្បីការផ្លាស់ប្តូរ នាខែមិនា ២០០៧។

ការតំឡើង ប្រាក់ឈ្នួលអប្បបរមារបស់កម្មកររោងចក្រដល់ ហាសិបដុល្លា(៥០ដុល្លា) កាលពីដើមឆ្នាំ ២០០៧ កន្លងមកនេះ គឺជាការផ្លាស់ប្តូរវិជ្ជមានមួយនៅក្នុងប្រវត្តិនៃការតស៊ូរបស់កម្មករ ប៉ុន្តែអ្វីដែលគួរអោយកត់សំគាល់នោះគឺតំលៃទំនិញ គ្រប់ប្រភេទ ថ្លៃទឹក ថ្លៃភ្លើង ថ្លៃធ្វើដំណើរ ដែលកម្មករត្រូវចំណាយជាប្រចាំនោះក៏បានឡើងដែរ។ កម្មករត្រូវបង្ខំឱ្យ ធ្វើការថែមម៉ោង ដើម្បីទទួលបានប្រាក់បន្ថែមដែលអាចឱ្យពួកគេរស់នៅបាន។ ការធ្វើការច្រើនម៉ោងមិនត្រឹមតែធ្វើឱ្យ កម្មករទ្រុឌទ្រោមសុខភាពប៉ុណ្ណោះទេ តែពួកគេក៏ប្រឈមមុខនឹងអសន្តិសុខ និងអំពើហឹង្សាពីសំណាក់ក្រុមជើងកាង នៅពេលពួកគេចេញពីធ្វើការនៅពេលយប់។

ទោះបីជាកំណើនសេដ្ឋកិច្ចកម្ពុជានៅតែបន្តកើនឡើង (១០.៦% នៅឆ្នាំ២០០៦) ដែលមួយចំណែកធំបានមកពីការនាំចេញផលិតផលសំលៀកបំពាក់កាត់ដេរក៏ដោយ ក៏កម្មកររោងចក្រកាត់ដេរមិនបានទទួលនូវផលប្រយោជន៍ដែលពួកគេគួរតែទទួលបាននោះដែរ។ ក្រោមសំពាធពីសំណាក់ថៅកែរោងចក្រកាត់ដេរក្នុងលេសថានឹងមានការបង្កើនការងារ និងទាក់ទាញដល់វិនិយោគទុន រដ្ឋាភិបាលកម្ពុជានាពេលថ្មីៗនេះ បានផ្ញើលិខិតមួយទៅកាន់រដ្ឋសភាជាតិកម្ពុជា ស្នើសុំឱ្យរដ្ឋសភាធ្វើវិសោធនកម្មច្បាប់ ដែលនឹងកាត់ប្រាក់កំរៃកម្មករធ្វើការងារវេនយប់ពី ២០០% មកនៅត្រឹម ១៣០%។

ដូចច្នេះ ទិវានេះជាទិវាមួយដែលមានសារៈសំខាន់ក្នុងការបង្ហាញ ពីផ្នែកមួយទៀតនៃលក្ខខណ្ឌការងារដែលកម្មករកម្មការិនីបាននិងកំពុងជួបប្រទះនៅក្នុងរោងចក្រ ។ បញ្ហាទាំងនេះគួរតែត្រូវបានលើកឡើងដើម្បីធ្វើការផ្លាស់ប្តូរធ្វើឱ្យស្ថានភាពលក្ខខណ្ឌការងារ នឹងស្ថានភាពរស់នៅរបស់ពួកគេឱ្យមានភាពប្រសើរឡើង។

*ពេលវេលា:* *៩:០០-១២:០០ ថ្ងៃត្រង់*

*ទីតាំង:* *ការិយាល័យអង្គការកម្មវិធីស្ត្រីដើម្បីការផ្លាស់ប្តូរ អតីតវង្គសាលវិមានគង្គារ ផ្ទះលេខ២០១ ផ្លូវ ស៊ីសុវត្ថិ សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ។*

*សំរាប់ពត៏មានបន្ថែមសូមទំនាក់ទំនង លោក សំ វុទ្ធី អ្នកសំរបសំរួល អង្គការកម្មវិធីស្ត្រីដើម្បីការផ្លាស់ប្តូរ តាមរយៈទូរស័ព្ទលេខ ០១២ ៩១៥ ០៨៤ ឬ ០១២ ២២២ ១៧១*